# យកលុយទៅប្រើការ
# សន្សំលុយដើម្បីសាងទ្រព្យ

កំរងសៀវភៅនេះមានពត៌មានពីសារសំខាន់នៃការសន្សំលុយ គំរោងក្នុងរយៈពេលខ្លីទៅរយៈពេលវែង ដើម្បីសន្សំលុយ បើកគណនីសន្សំ ហើយនឹងវិធីធ្វើឲ្យលុយកើនឡើងយ៉ាងឆាប់រហ័សដូចជាការទុកលុយ ដោយមានលិខិតបញ្ជាក់ Certificates of Deposit (CDs) គណនីសន្សំសំរាប់វ័យចាស់ (IRAs) U.S. Saving bonds ហើយនិងគណនីសន្សំសំរាប់មហាវិទ្យាល័យ ។

ការបោះពុម្ភនេះជាផ្នែកមួយ នៃការបង្រៀងពីការសន្សំលុយដើម្បីសាង ទ្រព្យ ។

## មាតិការរឿង


* ចាប់ផ្តើមពីសន្សំលុយ
* ត្រូវប្រើពេលវេលា
* ការប្រាក់
* តាក់ល្អិតលុយសន្សំច្រើន
* ពិន្ទុឆ្ពោះទៅគោលដៅ
* រកកន្លែងទុកលុយ
* គណនីសន្សំ
* រៀបចំបើកគណនី
* យកឲ្យច្រើនពីលុយសន្សំ
* ធ្វើវិនិយោគជាមួយរដ្ឋាភិបាល
* ដកតាក់សំរាប់ចូលនិវត្តិ
* សន្សំក្នុងកន្លែងធ្វើការ
* គ្រោះថ្នាក់និងរង្វាន់

## ចាក់ផ្ដើមពីសន្សំលុយ

សាងទ្រព្យគឺដូចជាសង់របងថ្ម ។ លោកអ្នកយកថ្មមួយដុំទៅដាក់លើថ្មមួយដុំទៀតហើយត្រូវឲ្យច្បាស់ថាជញ្ជាំងនោះត្រូវរឹងមាំមុននឹងដាក់ដុំជាបន្ទាប់ទៅទៀត ។ សន្សំលុយដើម្បីសាងទ្រព្យគឺដូចគ្នា ។ លោកអ្នកត្រូវរៀបចំគំរោងហើយប្រឹងប្រែងដើម្បីឈានទៅរកដុំថ្ម ជាបន្ទាប់ហើយជួរបន្ទាប់ទៀត ។ លោកអ្នកអាចនឹងគិតថាពិបាកនិងសន្សំលុយណាស់ ។ ប៉ុន្តែបើទុកដោយឡែកទោះបីជាតិចនោះអាចទៅជាច្រើនដែលអាចជួយលោកអ្នកបានក្នុងពេលអាសន្ន កំរិតខ្ចីដូចជាជួសជុលឡាន ឬទិញសម្ភារៈប្រើប្រាស់ក្នុងផ្ទះ ។

## ត្រូវប្រើពេលវេលា

លោកអ្នកមិនអាចសាងទ្រព្យក្នុងពេលតែមួយយប់នោះទេ ។ គំរោងដ៏ល្អទីមួយគឺសន្សំលុយសំរាប់ពេលអាសន្ន ។ គណនីសន្សំគឺជាលុយ ដែលលោកអ្នកទុកដោយឡែក សំរាប់យកមកប្រើពេលគ្មានការធ្វើ ឬមានគ្រោះថ្នាក់ មិនអាចទៅធ្វើការបាន ។ លុយបំរុងសំរាប់ពេលអាសន្នត្រូវមានចំនួនស្មើនឹងប្រាក់ខែពី 3 ទៅ 6 ខែ ។ លុយនេះសំរាប់យកមកប្រើពេលមានអាសន្ន ដែលមិនអាចស្មានបានដូចដូចជាជួសជុលឡាន ឬផ្លាស់ប្ដូរសម្ភារៈក្នុងផ្ទះ ។

## ការប្រាក់

ការប្រាក់ជាថ្លៃនៃការចាយលុយ ។ ធនាគារឲ្យការប្រាក់ទៅលើលុយដែលលោកអ្នកទុកក្នុងធនាគារ ។ បើលោកអ្នកខ្ចីលុយនោះត្រូវបង់ការប្រាក់ទៅឲ្យម្ចាស់ប្រាក់ ។ ស្ថាប័នសន្សំលុយប្រើសំបុត្រ APY (Annual Percentage Yield) បន្ទាប់ពីគិតការប្រាក់ ។ នេះជាចំនួនលុយបានមកពីការទុកលុយក្នុងរយៈពេលមួយឆ្នាំ ។ ការប្រាក់មានពីរប្រភេទ គឺប្រភេទធម្មតានិងប្រភេទរួមគ្នា ។ ការប្រាក់ធម្មតាបង់ឲ្យលោកអ្នកចំពោះតែលុយដែលដាក់ប៉ុណ្ណោះ ឯការប្រាក់រួមគ្នាគឺប្រ

សើរណាស់ ព្រោះលោកអ្នកបានកំរៃមិនត្រឹមតែលើលុយដែលយកទៅដាក់ទេ គឺបានពីលើការប្រាក់បន្ថែមទៀត

## កាត់ល្អិតលុយសន្សំច្រើន

កាត់ការចំណាយរៀងរាល់ថ្ងៃ អាចជួយកុំឲ្យលោកអ្នកចាយលុយខ្ជះខ្ជាយ ហើយអាចបង្កើតជាថវិកាបាន ។ ថវិកាជាគំរោងចាយលុយដែលអាចជួយឲ្យលោកអ្នកគិតគូរ ជាមុនហើយគ្រប់គ្រងចំណាយបាន ។ ដឹងថាអ្វីដែលគួរចាយនោះគឺជាជំហានទីមួយហើយក្នុងការបង្កើតជាថវិកា ។

មនុស្សច្រើនណាស់ដែលរកឃើញថាកាក់ល្អិតអាចបូកឲ្យទៅជាលុយសន្សំបានយ៉ាងច្រើន ។ ដើម្បីបង្កើតជាថវិកាលោកអ្នកត្រូវដឹងថាតើត្រូវចាយលុយប៉ុណ្ណាដែរក្នុងមួយខែៗហើយយកមកធៀបជាមួយលុយដែលយកមកផ្ទះ ។ កាលបើលោកអ្នកអាចរៀបចំថវិកាហើយប្រើវិធីនេះជាច្រើនអាទិត្យលោកអ្នកនឹងឃើញថាអ្វីទៅដែលត្រូវកាត់ផ្តាច់នោះ ។ បើលោកអ្នកចាយតិចជាងលុយរកបានលោកអ្នកពិតជាសល់លុយហើយ ។

## ពន្លឺឆ្ពោះទៅគោលដៅ

គោលដៅខាងលុយកាក់គឺជាបំណងផ្ទាល់ខ្លួនដែលលោកអ្នកគ្រងទុកសំរាប់ខ្លួនក្នុងជីវិត ។ គឺជាប្រភេទរយៈពេលខ្លី និងរយៈពេលវែង ។ ដឹងពីគោលបំណងអាចជួយឲ្យលោកអ្នកសន្សំលុយបានច្រើន ។ រយៈពេលខ្លីគឺចង់ឲ្យបានសំរេចក្នុងមួយឆ្នាំ ឬពីរឆ្នាំដូចជាបញ្ចប់ការសិក្សា ឬទិញឡាន ។

រយៈពេលវែងប្រហែលជាយូរ ទើបបានសំរេច ឬអាចជាប្រើពេលក្នុងកំឡុងប្រាំឆ្នាំ ឬយូរជាងនេះដើម្បីអាចទិញផ្ទះ ឬយូរជាងនេះទៅទៀតដើម្បីសន្សំឲ្យបានច្រើនគ្រប់គ្រាន់សំរាប់ពេលចូលនិវត្តន៍ យ៉ាងសុខសាន្ត ឬក៏បង់ថ្លៃវិទ្យាល័យឲ្យកូនៗ ។

## ទុកប្រាក់ពេលអាសន្ន

ជាការប្រសើរណាស់ ដែលលោកអ្នកអាចទុកលុយ សំរាប់ពេលមានអាសន្ននេះ ក្នុងគណនីហើយអាចបើកបានយ៉ាងរហ័ស និងយ៉ាងងាយស្រួលពេលត្រូវការ ។ ( បើលោកអ្នកបានទទួលជំនួយពីរដ្ឋ ប្រហែលជាមានការកំរិត ថាតើអាចមានលុយប៉ុណ្ណាដែរក្នុងគណនីសន្សំ ) ។ មុននឹងចាប់ផ្តើមសន្សំលុយ គួរពិគ្រោះជាមួយទីប្រឹក្សាខាងផលប្រយោជន៍ ។

## លុយដែលអាចបើកបានភ្លាមៗហៅថាដូរជាប្រាក់បាន

លោកអ្នកអាចទុកលុយដែលអាចបើកបានភ្លាមវិញ ក្នុងគណនីសន្សំឬក្នុងកុងរបស់ Credit union share, money deposit account ឬការដាក់លុយមានសំបុត្របញ្ជាក់ក្នុងរយៈពេលខ្លី (CD) ។

ក្នុងគណនីសន្សំដែលធានារ៉ាប់រងដោយរដ្ឋាភិបាល លោកអ្នកមិនបានការប្រាក់ច្រើនទេប៉ុន្តែមានសន្តិសុខ ហើងាយស្រួលក្នុងប្រើ ។ ការដាក់លុយមានសំបុត្របញ្ជាក់ក្នុងរយៈពេលខ្លី (CD) អាចឲ្យការប្រាក់ច្រើនបន្តិចពីគណនីសន្សំ ។ លោកអ្នកអាចដាក់លុយក្នុងរយៈពេលខ្លីចំនួនមួយខែទៅក្នុង (CD) នៅក្នុង Internet bankrate.com អាចជួយឲ្យលោកអ្នកធ្វើការប្រៀបធៀបការប្រាក់ពីស្ថាប័នផ្សេងៗ ។

**គណនីសន្សំ ។** គណនីសន្សំបង្កើតឡើងសំរាប់រក្សាលុយរបស់លោកអ្នកហើយធ្វើឲ្យលុយកាន់តែកើន ។ គណនីក្នុងធនាគារបានត្រូវធានាដោយសហព័ន្ធមានចំនួនរហូតដល់ 250,000 ។ ធនាគារឲ្យការប្រាក់លើលុយដែលលោកអ្នកមានក្នុងគណនី ។ លោកអ្នកអាចយកលុយទៅដាក់ ហើយបើកមកវិញពេលត្រូវការ។ ដូចជាធនាគារផ្សេងៗដែរ Credit union ផ្តល់គណនីសន្សំ (ហៅថាគណនីរួមគ្នា) ព្រមទាំងសេវាខាងលុយកាក់ផ្សេងៗ ។ Credit union គឺជាកន្លែងសន្សំដោយ

គ្មានគិតកំរៃ ហើយជាក្រុមហ៊ុនឲ្យខ្ចីលុយដែលផ្តល់សេវាឲ្យសមាជិករបស់គេ ដែលមានប្រភពលុយជាមួយគ្នា ដូចជាធ្វើការនៅក្នុងក្រុមហ៊ុនជាមួយគ្នារស់ក្នុង សង្គមជាមួយគ្នា ឬក៏ជាសមាជិក នៃវិហារកាតូលិចដូចគ្នា ។ ការដាក់លុយក្នុង គណនី Credit union របស់សហព័ន្ធ និងត្រូវបានធានាដោយប្រាក់ចំនួន 250,000 តាមរយៈ National Credit Union Administration (NCUA) ។

គណនីអភិវឌ្ឍន៍ជាឯកជន Individual development accounts (IDAs) គឺជាគណនីសន្សំពិសេសដែលអាចជួយគ្រួសារដែលមានប្រាក់ខែតិចឲ្យសន្សំ លុយសំរាប់រៀនបន្ត ឬហ៊ីកហ្វឹនការងារ ទិញផ្ទះឬធ្វើជំនួញ ។ ស្ថាប័នឯកជននឹង សាធារណៈផ្តត់ផ្គង់ការបរិច្ចាគរបស់លោកអ្នក ។ អ្នកចូលជាសមាជិកនៃ IDA ភាគច្រើនត្រូវតែរៀន ដើម្បីកែសំរួលប្រវត្តិនៃការជំពាក់លុយរបស់គេ បង្កើតជា ថវិកា ហើយប្រើប្រាស់គណនីសន្សំរហូតទៅ ។ សុំរកសៀវភៅរាយឈ្មោះយ៉ាង ទូលំទូលាយ របស់ IDA នៅ www.idanetwork.org ចុចត្រង់ IDA Directory ហើយ ដាក់ឈ្មោះនិងលេខទីក្រុង ដើម្បីរកកម្មវិធីក្នុងស្រុករបស់ IDA ។

## បើកគណនី

ដើម្បបើកគណនីសន្សំ ធនាគារភាគច្រើនតំរូវឲ្យមានប័ណ្ណសំគាល់ខ្លួនពីរច្បាប់ មួយច្បាប់មានរូបថត ។ លោកអ្នកត្រូវមានលេខប្រចាំខ្លួនដើម្បីបើកគណនី ។ ចំនួនប្រាក់ដែលគេតំរូវឲ្យដាក់ជាលើកដំបូងនោះគឺមិនទៀងទាត់ ។ ធនាគារខ្លះ តំរូវត្រឹមតែមួយ $1 ដុល្លាខ្លះ $ 50 ដុល្លាខ្លះ $100 ឬ $ 500 ដុល្លា ។ លោកអ្នក អាចដាក់លុយសុទ្ធ ឬសែកដើម្បីបើកគណនី ។

ពេលបើកគណនី ប្រវត្តិខាងគណនី នឹងត្រូវបានពិនិត្យដោយក្រុមហ៊ុនឆែកឆេរ ដូចជា ChexSystems ។ បើលោកអ្នកមានបញ្ហាខាងគណនីដូចជាបិទគណនី ដោយ សរសេរសែកគ្មានលុយ ហើយនៅជំពាក់ធនាគារនោះ

លោកអ្នកច្បាស់ជាត្រូវ ធនាគារបដិសេធហើយ ។ ដើម្បីឲ្យដឹងច្បាស់ថាម៉េចបានជាគេបដិសេធត្រូវ online www.chexhelp.com

ដើម្បីឲ្យបានទទួលការចម្លងពីប្រវត្តិធនាវគារឈ្មោះថារបាយកាណ៍នៃអ្នកប្រើប្រាស់ ។បើក្រុមហ៊ុននោះឲ្យពត៌មានខុសលោកអ្នក មានសិទ្ធិនឹងបញ្ជាក់ថាខុស ។

## អ្វីដែលបានច្រើនបំផុតពីការសន្សំ

បើលោកអ្នកសន្សំទៀងទាត់ ថ្ងៃដែលលោកអ្នកអាចបង្កើតជាទ្រព្យហើយរកលុយបានកាន់តែច្រើននុះនឹងមកដល់ ។ ទ្រព្យទាំងនេះមានលុយក្នុងគណនីសន្សំលុយសំរាប់ចូលនិវត្តន៍ Stock's bonds ផ្ទះនិងដីធ្លី ។នៅសហរដ្ឋអាមេរិកប្រភពនៃទ្រព្យគឺជាតម្លៃនៃផ្ទះ ។

ទីប្រឹក្សាឯកទេសជាច្រើនបានឲ្យយោបល់ថា លោកអ្នកត្រូវសន្សំឲ្យបាន 10% ជារៀងរាល់ឆ្នាំ ។ បើជាការពិបាកពេក សុំចាប់ផ្តើមពីចំនួនតិច ។ ដើម្បីបង្ខំខ្លួនឯងឲ្យចេះសន្សំត្រូវចាប់ផ្តើមដាក់លុយរៀងរាល់ពេលទទួលប្រាក់ខែទៅក្នុងគណនីសន្សំ ឬទៅក្នុងគណនីសំរាប់ពេលចូលនិវត្តន៍ (IRA) ។

ការដាក់លុយដោយមានលិខិតបញ្ជាក់ (CDs) ឬអាចហៅថាគណនីសន្សំមានពេលគឺជាវិធីសុខសាន្តសំរាប់ធ្វើឲ្យលុយរីកដុះដាល ។ CDs ខ្លះចេញឲ្យដោយធនាគារប៉ុន្តែលោកអ្នកអាចទិញពីអ្នកនាំសារជំនួញបានដែរ ។ CDs ដែលលក់ចេញពីធនាគារ ឬពីអ្នកនាំសារជំនួញសុទ្ធតែបានធានាដោយ (FDIC) ក្នុងចំនួនទឹកប្រាក់ដល់ទៅ 250,000 ក្នុងមនុស្សម្នាក់ ៗ ។

ការប្រាក់នៃ CD ចុះឡើងជាខ្លាំងហើយខ្ពស់ជាងការប្រាក់ពីគណនីសន្សំ ។ បើលោកអ្នកទុកលុយក្នុង CD ក្នុងរយៈពេលជាក់លាក់នោះលោកអ្នកនឹងបាន

ទទួលអត្រាការប្រាក់ខ្ពស់ ។ ជាទូទៅកាន់តែទុកលុយក្នុងគណនីយូរប៉ុណ្ណា ការប្រាក់ក៏ច្រើនប៉ុណ្ណោះដែរ ។ ពេលវេលាគឺក្នុងកំឡុងពី មួយខែទៅប្រាំមួយឆ្នាំ ។ បើលោកអ្នកបើកលុយមុនពេលកំណត់ លោកអ្នកនឹងត្រូវគេផាកពិន័យ ។

**ធ្វើវិនិយោគទុនក្នុងរដ្ឋាភិបាលសហរដ្ឋអាមេរិក**

រកធានាគារយ៉ាងមានសន្តិសុខ គឺជាវិនិយោគយ៉ាងសុខសាន្ត ព្រោះមានការធានាពីរដ្ឋាភិបាលសហរដ្ឋអាមេរិក ។ Saving bonds ដែលចុះថ្លៃពីតម្លៃពេញពេលដល់កំណត់អាចបើកបាន ។ ការប្រាក់អាចចុះឡើងប៉ុន្តែលោកអ្នកត្រូវបានទទួលតម្លៃយ៉ាងខ្ពស់ ។ Saving bonds អាចបើកបានចំពោះតែអ្នកដែលចុះឈ្មោះទិញប៉ុណ្ណោះ ។

លោកអ្នកអាចទិញ Series EE ( ធានាថាមានតម្លៃពេញក្នុងរយ: 20ឆ្នាំ ) ឬ Series I ( អាចបញ្ចុះ ឬតម្លើងបាន ) bonds ។ EE bonds លក់ក្នុងតម្លៃ 50% នៃតម្លៃពិត ( $ 100 EE bonds ថ្លៃ $ 50 ) Series I Bonds ថ្លៃក្នុងតម្លៃពិត( $ 100 I bonds ថ្លៃ $ 100 ) ហើយបានការប្រាក់ដែលចុះឡើងពីរដងក្នុងមួយឆ្នាំ ។ បើចង់ បានពត៌មានបន្ថែមសុំមើលក្នុង website (www.savingbonds.gov) ។

**លុយមិនបង់តាក់សំរាប់ពេលចូលនិវត្តន៍**

គណនីផ្ទាល់ខ្លួនសំរាប់ពេលចូលនិវត្តន៍ (IRAs) ជាគណនិសន្សំបង្កើតឡើងសំរាប់ជួយមនុស្សឲ្យទុកលុយដោយឡែកសំរាប់ពេលចូលនិវត្តន៍ ។ ដើម្បីឲ្យដឹងច្បាស់ពីចំនួនដុល្លាចុងក្រោយ ដែលកំណត់ក្នុងចំនួន វិភាគទានប្រចាំឆ្នាំនៃ IRA សុំមើល Internal Revenue Service Website at www.irs.gov ។ សរសេរ "Publication 590 "ក្នុង Search box ដើម្បីឲ្យដឹងច្រើនជាងនេះ ។ ច្បាប់នៃសហព័ន្ធតំរូវថា IRA ត្រូវតែគ្រប់គ្រងដោយអាណាព្យាបាលដូចជាធនាគារ Credit Union ក្រុមហ៊ុនធានារ៉ាប់រង Mutual Fund ឬ brokerage firm.

IRA មានពីរប្រភេទគឺ Traditional IRAs និង Roth IRA

Traditional IRAs ជួយឲ្យលោកអ្នកបង់ income Tax ថោកបន្តិចព្រោះលោកអ្នកត្រូវដាក់លុយទៅក្នុងគណនីនោះមុនបង់តាក់ ហើយដកវិភាគទាននោះក្នុងឆ្នាំដដែល ។ លោកអ្នកមិនបាច់បង់តាក់លើលុយវិភាគទាន ឬលុយធ្វើវិនិយោគឡើយទាល់តែត្រូវការដកលុយតាមធម្មតាពេលមានអាយុ 59 ឆ្នាំកន្លះ ។ បើលោកអ្នកដកលុយពី IRA មុនអាយុនេះលោកអ្នកត្រូវបង់តាក់ចំនួន 10%លើចំនួន Income Tax ដែលត្រូវបង់

Roth IRA មិនមែនមិនបង់តាក់ទេ ( លោកអ្នកធ្វើវិនិយោគបន្ទាប់ពីបង់តាក់ ) ប៉ុន្តែមិនបាច់បង់តាក់លើលុយដែលកើននោះ ។

លោកអ្នកធ្វើវិភាគទានទៅលើ IRA និង Roth ប៉ុន្តែជាវិភាគទានមានកំរិត សុំអាន www.irs.gov ពីការកំរិតនេះ ។

បើលោកអ្នកមានអាយុច្រើនជាង 59ឆ្នាំកន្លះ ឬពិការ ការបើកលុយពី Roth IRA មិនត្រូវបង់តាក់ទេ បើគណនីនោះមានអាយុយ៉ាងតិច 5ឆ្នាំ ។ លោកអ្នកអាចបើកលុយមុនអាយុនេះ បើសិនជាមានការចាំបាច់ត្រូវទិញផ្ទះជាលើកដំបូង ឬត្រូវបង់ថ្លៃពេទ្យដោយចេញលុយពីហោប៉ៅ (out of pocket)

ចង់ដឹងពីការលើកលែងខ្លះ ឬពត៌មានបន្ថែមពី IRAs សុំអាន (www.irs.gov)

## សន្សំសំចៃក្នុងកន្លែងធ្វើការ

កុំឲ្យបាត់ឱកាសសន្សំលុយក្នុងកន្លែងធ្វើការ ។ និយោជិកខ្លះមិនសន្សំលុយក្នុងគណនីសំរាប់ពេលចូលនិវត្តន៍ទេ ព្រោះលុយត្រូវយកទៅផ្ទះមានចំនួនតិច ។ ប៉ុន្តែលោកអ្នកអាចសន្សំលុយបានកាន់តែច្រើន ក្នុងឱកាសដែលនិយោជកបន្ថែមលុយរបស់គេទៅលើប្រាក់សន្សំនោះ ។ លុយបន្ថែមនេះមានកំរិតដូច្នេះ បើលោកអ្នកធ្វើវិនិយោគទៅលើលុយមុនបង់តាក់ លោកអ្នកត្រូវទទួលវិភាគ

ទានពីនិយោជក ។ ពេលត្រូវធ្វើតាក់លោកអ្នកជំពាក់គេតិចព្រោះថាផ្នែកខ្លះនៃប្រាក់ខែរបស់លោកអ្នកដែលធ្វើជាវិភាគទាននោះមិនបានត្រូវគិតតាក់ទេ ។ លោកអ្នកប្រហែលជាត្រូវបានគេតំរូវឲ្យចាត់ចែងរឿងវិនិយោគទុននេះដោយខ្លួនឯងក្នុងមួយផ្នែក ឬក្នុងចំនួនទាំងអស់នៃវិនិយោគនេះ ។ ត្រូវពិភាក្សាជាមួយអ្នកជំនួយការខាងក្រសួងស៊ើបអង្កេតក្នុងរឿងនេះ ដើម្បីឲ្យច្បាស់ថាតើគណនីរបស់លោកអ្នកនោះមានវិនិយោគច្រើនមុខ ផ្សេងៗពីគ្នាដែរទេ គណនីនេះមានវិនិយោគចំរុះគ្នាផ្សេងៗជាច្រើនមិនមែនគ្រាន់តែជា stocks របស់និយោជិកនោះទេ ។

## គ្រោះថ្នាក់និងរង្វាន់

មនុស្សម្នាក់ៗសុទ្ធតែចង់បានចំណេញច្រើនក្នុងការទុកលុយ ។ ប៉ុន្តែរកលុយបានច្រើនប៉ុណ្ណាគ្រោះថ្នាក់ពីការខាតបង់លុយក៏ច្រើនប៉ុណ្ណោះដែរ ។ គណនីសន្សំនិង CD ពីធនាគារដែលធានារ៉ាប់រង់ដោយ FDIC ផ្តល់ប្រាក់ចំណេញតិចជាងវិនិយោគផ្សេងៗទៀតព្រោះសុវត្ថិភាព ។ ផ្ទុយពីនេះ Stocks Bounds Mutual Funds គ្មានការធនាទេ ហើយអាចបានចំណេញច្រើនក្នុងរយៈកាលយូរ ។ ពេលដែលលោកអ្នកគិតពីរឿងវិនិយោគ សំខាន់បំផុតត្រូវសាកសួរពីប្រាក់ចំណេញ និងគ្រោះថ្នាក់ ( ឬអាចដកលុយបានឆាប់ប៉ុណ្ណាពេលត្រូវការ ) មិនគួរឲ្យជឿថាលោកអ្នកអាចធ្វើវិនិយោគតែមួយគត់តែអាចផ្តល់បីមុខដ៏ប្រសើរគឺប្រាក់ចំណេញច្រើន មានគ្រោះថ្នាក់តិចបំផុត ហើយងាយស្រួលក្នុងការបើក ។ អាចជាមានគ្រោះថ្នាក់ចំពោះមនុស្សម្នាក់ៗក្នុងការទិញ Stock ។ កុំស្តាប់យោបល់គេពីរឿង Stock ឲ្យសោះក្រៅពីសាកសួរពត៌មានដោយខ្លួនឯង ។ គ្មានការធានាថាតម្លៃរបស់ Stock ឡើងឬក៏លោកអ្នកអាចបានចំណេញ ច្រើនពីការទិញ Stock ឡើយ ។

មនុស្សភាគច្រើនធ្វើវិនិយោគដោយទិញ Mutual Funds ច្រើនមុខផ្សេងៗ ឬផ្សេងនឹងគ្រោះថ្នាក់ដោយទិញ Stock Mutual Funds ជាផលប័ត្រ របស់ Stock Bonds ហើយនិងប្រាក់ធានាផ្សេងៗ ដែលប្រជាជនអាចទិញជាហ៊ុន ។ អ្នកធ្វើវិនិយោគដោយទិញហ៊ុនអាចបានចំណេញ ខាតហើយត្រូវចាយប្រាក់ជាច្រើន ។ លោកអ្នកអាចខាតលុយក្នុង Mutual funds នេះដែរ ។

## ពត៌មានបន្ថែម

America Saves (www.americansaves.org) ផ្តល់ភាពជាសមាជិកដោយឥតគិតថ្លៃ ហើយឲ្យឱកាតពីកំពោងធ្វើថវិកាទៅអ្នកដែលសន្យាថា នឹងសន្សំព្រមទាំងទុកចំនួនលុយរៀងរាល់ខែឆ្ពោះទៅកាន់គោលដៅ ។ Bank rate (www.bankrate.com) ផ្តល់អត្រាការប្រាក់នៃ CDs និង Money Market Accounts Choose to save (www.choosetosave.org)ផ្តល់ឱវាទពីការសន្សំលុយសំរាប់ មហាវិទ្យាល័យ ទិញផ្ទះ ហើយនិងការចូលនិវត្តន៍ ។

ចប់2